

# ពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុនសម្រាប់ការផ្តល់ជូនក្នុងឆ្នាំ ២០២៦

សូមប្រគល់លិខិតនេះ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៦

ខ្ញុំ បានចុះហត្ថលេខា: ☐ លោក ☐ លោកស្រី

**ព័ត៌មានផ្ទាល់ខ្លួន**

គោត្តនាម: ______________________ នាម: ______________________

ថ្ងៃខែឆ្នាំកំណើត: ______________________ សញ្ជាតិ: ______________________

និយោជក: ______________________ អត្តលេខក្នុង VINCI group: ______________________

អាសយដ្ឋានផ្ទាល់ខ្លួន: ______________________

លេខកូដប្រៃសណីយ៍: __________ ទីក្រុង: __________ ប្រទេស: __________

អ៊ីមែល: ______________________ លេខទូរសព្ទដៃ: ______________________

**ព័ត៌មានដែលតម្រូវឱ្យមានខាងលើនេះ មានសារៈសំខាន់ក្នុងដំណើរការពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុនរបស់លោកអ្នក និងក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់លោកអ្នក។ សូមបំពេញគ្រប់ចន្លោះទាំងអស់មុននឹងបញ្ជូនពាក្យស្នើសុំចុះឈ្មោះទិញនេះរបស់លោកអ្នក។**

ខ្ញុំសូមបញ្ជាក់ថា៖

- ខ្ញុំបានអាន និងបានយល់នូវ **ឯកសារពាក់ព័ន្ធនឹងការផ្តល់ជូន** ដែលខ្ញុំអាចទទួលបានក្នុង **castor.vinci.com**។

- ខ្ញុំបានកត់សម្គាល់អំពី**តម្លៃនៃការទិញភាគហ៊ុននេះ**។
- ខ្ញុំបានកត់សម្គាល់ **អំពីបញ្ញត្តិដែលមានចែងនៅខាងខ្នងនៃពាក្យស្នើសុំនេះ** និង**ទទួលយកការចងភ្ជាប់កាតព្វកិច្ចជាមួយប្រការទាំងនោះ**។

**ខ្ញុំសូមបញ្ជាក់បន្ថែមទៀតថា៖**

- ខ្ញុំគឺជា**និយោជិត**របស់ក្រុមហ៊ុនរបស់ VINCI group។
- នៅថ្ងៃទិញភាគហ៊ុននេះ **ខ្ញុំបានធ្វើការជានិយោជិតរបស់ VINCI group បានរយៈពេលយ៉ាងតិចប្រាំមួយខែ** (ជាប់គ្នា ឬ មិនជាប់គ្នា) ក្នុងរយៈពេលដប់ពីរខែកន្លងទៅនេះ។

**ខ្ញុំបានសម្រេចចិត្តធ្វើការវិនិយោគ (អប្បបរមា ១ ភាគហ៊ុន)** ................ **ភាគហ៊ុន*** **ក្នុងការផ្ដល់ជូននេះ ក្នុងទឹកប្រាក់វិនិយោគចំនួន៖** ............... **ដុល្លារអាមេរិក****

* ភាគហ៊ុនត្រូវបានទិញតាមរយៈ FCPE Castor International Relais 2026 ដែលនឹងចេញឲ្យអ្នកនូវឯកតារបស់ FCPE ដែលសមស្របនឹងការវិនិយោគរបស់អ្នក។
**ខ្ញុំបញ្ជាក់ចំនួនទឹកប្រាក់ដែលសមស្របសម្រាប់ការទូទាត់របស់ខ្ញុំ និងសម្រាប់ការផ្ទៀងផ្ទាត់ថាវាមិនលើសពីកម្រិតវិនិយោគអតិបរមាដែលអនុវត្ត។
ដើម្បីគណនាចំនួនវិនិយោគ ខ្ញុំគុណចំនួនភាគហ៊ុនដែលខ្ញុំបានជ្រើសវិនិយោគជាមួយតម្លៃចុះឈ្មោះដែលខ្ញុំបានទទួលដឹង។ ខ្ញុំក៏អាចប្រើកម្មវិធីស៊ីម្យូលេត (simulator) ដែលមាននៅលើគេហទំព័រ។ **ក្នុងករណីមានភាពខុសគ្នា** រវាងសំណើចំនួនភាគហ៊ុន និងចំនួនទឹកប្រាក់សរុបដែលខ្ញុំបានបញ្ជាក់ជាដុល្លារអាមេរិក **សំណើរបស់ខ្ញុំនឹងត្រូវដំណើរការតាមចំនួនភាគហ៊ុន ហើយខ្ញុំនឹងនៅតែទទួលខុសត្រូវចំពោះនិយោជកសម្រាប់ភាពខុសគ្នា ប្រសិនបើមាន** (សូមមើលផ្នែក «ការខកខានក្នុងការទូទាត់ – ការទូទាត់យឺត» ខាងក្រោម)

ខ្ញុំទូទាត់នូវចំនួនសរុប (គូសក្នុងប្រអប់តែមួយប៉ុណ្ណោះ)៖

☐ **ជាការផ្ទេរតាមរយៈធនាគារ**

- ព័ត៌មានលម្អិតនៃគណនីធនាគារនឹងបញ្ជាក់មកខ្ញុំ ដោយ VINCI group។
- ការបង់ប្រាក់របស់ខ្ញុំត្រូវតែទទួលបានយ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦។

☐ **តាមរយៈការកាត់**នូវចំនួនដូចដែលបញ្ជាក់ខាងលើ**ពីប្រាក់បៀវត្សរបស់ខ្ញុំ**មានដូចខាងក្រោម៖

- ខែកក្កដា ឆ្នាំ២០២៦៖ ______ ដុល្លារអាមេរិក
- ខែសីហា ឆ្នាំ២០២៦៖ ______ ដុល្លារអាមេរិក
- ខែកញ្ញា ឆ្នាំ២០២៦៖ ______ ដុល្លារអាមេរិក
- ខ្ញុំអនុញ្ញាតឲ្យនិយោជករបស់ខ្ញុំកាត់ប្រាក់បៀវត្សទាំងនេះចេញពីប្រាក់បៀវត្សរបស់ខ្ញុំដូចដែលបានបញ្ជាក់ខាងលើ។ សូមកត់សម្គាល់ថា ការកាត់នឹងធ្វើឡើងស្របតាមច្បាប់ដែលពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា។ ជាពិសេស ការកាត់ប្រាក់បៀវត្សមិនត្រូវលើសពីចំណែកដែល "អាចផ្ទេរបាន ឬរឹបអូសបាន" នៃប្រាក់បៀវត្សរបស់ខ្ញុំដូចមានចែងក្រោមច្បាប់ស្ដីពីការងារឡើយ។ ដូច្នេះ ខ្ញុំអះអាងថាការបង់ប្រាក់ជាដំណាក់កាលនីមួយៗនឹងមិនរារាំងសមត្ថភាពរបស់ខ្ញុំក្នុងការរក្សាបាននូវកម្រិតជីវភាពសមរម្យដោយផ្អែកលើលក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ននោះទេ។

**សម្រាប់និយោជិតដែលបានចូលរួមក្នុងគម្រោង Castor 2023៖**

☐ **តាមរយៈការកាត់ប្រាក់ដែលបានពីការលក់ទៅវិញនៃភាគហ៊ុនរបស់ខ្ញុំ** ដែលមាននៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៦ ដោយអនុលោមតាមការជូនដំណឹងរបស់ខ្ញុំស្តីពីការចាកចេញពីគម្រោង Castor 2023 និងអនុវត្តការជូនដំណឹងរបស់ខ្ញុំមុនថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៦។

- បានកត់សម្គាល់ថា ប្រសិនបើការស្នើសុំលក់ទៅវិញមិនបានចាប់ផ្តើមនៅត្រឹមថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៦ នោះទេ តម្លៃទិញនឹងត្រូវបានបង់តាមរយៈការកាត់ប្រាក់បៀវត្សរបស់ខ្ញុំជាដំណាក់កាលក្នុងទឹកប្រាក់ស្មើៗគ្នា ក្នុងអំឡុងខែកក្កដា សីហា និងកញ្ញា ឆ្នាំ២០២៦ ឬ រយៈពេលយូរជាងនេះ យោងតាមចំនួនប្រាក់បៀវត្សអប្បបរមាដែលត្រូវបានធានា។

## ខ្ញុំបានកត់សម្គាល់យ៉ាងត្រឹមត្រូវថា៖

### ឯកសារ

ការផ្តល់ជូននេះ **ត្រូវបានគ្រប់គ្រង**ដោយបញ្ញត្តិនៃផែនការនៃការសន្សំ និងការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Saving and Share Ownership Plan) របស់ VINCI group បញ្ញត្តិនៃពាក្យចុះឈ្មោះស្នើសុំទិញភាគហ៊ុននេះ បទប្បញ្ញត្តិ និងឯកសារព័ត៌មានសំខាន់ៗរបស់ FCPE CASTOR INTERNATIONAL RELAIS 2026 និង FCPE CASTOR INTERNATIONALឯកសារបន្ថែមតាមប្រទេស (Local Supplement) ព្រមទាំងលិខិតបញ្ជាក់ដោយសាម៉ីខ្លួន។

ខ្ញុំអាច**ពិគ្រោះ**ឯកសារទាំងនេះ ព្រមទាំងខិត្តប័ណ្ណព័ត៌មានសង្ខេបមាននៅក្នុង **castor.vinci.com**។

### ការវិនិយោគ

### ក្នុងភាគហ៊ុនរបស់ VINCI

ចំនួនទឹកប្រាក់ដែលត្រូវគ្នានឹងការទិញភាគហ៊ុនរបស់ខ្ញុំនឹងត្រូវបានវិនិយោគ**នៅក្នុងភាគហ៊ុនរបស់ VINCI**៖

- ជាដំបូង ភាគហ៊ុនរបស់ខ្ញុំនឹងត្រូវបានទុកនៅក្នុង FCPE CASTOR INTERNATIONAL RELAIS 2026។
- បន្ទាប់មក ក្រោយពីការបញ្ចូលរបស់ FCPEs ភាគហ៊ុនរបស់ខ្ញុំនឹងទុកនៅក្នុង FCPE CASTOR INTERNATIONAL។

### ពាក្យស្នើសុំដែលមិនអាចដកវិញបាន

ពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុនរបស់ខ្ញុំ**នឹងមិនអាចដកវិញបានទេ នៅពេលបញ្ចប់រយៈពេលចុះឈ្មោះទិញ**។ ប្រសិនបើខ្ញុំដាក់ពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុនជាទម្រង់ក្រដាស និងការស្នើសុំចុះឈ្មោះទិញភាគហ៊ុនតាមប្រព័ន្ធអនឡាញ មានតែការចុះឈ្មោះទិញភាគហ៊ុនជាទម្រង់ប្រព័ន្ធអនឡាញតែប៉ុណ្ណោះដែលនឹងត្រូវដំណើរការ។

### បំពេញទម្រង់បែបបទ

**ប្រសិនបើមិនទាន់បានបំពេញត្រឹមត្រូវ ឬមានការភ័ន្តច្រឡំ រាល់ពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុនអាចត្រូវបានបដិសេធ**។ ជាពិសេស VINCI អាចចាត់ទុកថា ពាក្យស្នើសុំរបស់ខ្ញុំមិនមានសុពលភាព ប្រសិនបើមិនមានភ្ជាប់ជាមួយនូវប្រាក់ថ្លៃភាគហ៊ុនដូចដែលបានកំណត់ខាងលើ។

**ខ្ញុំសូមយល់ព្រមយ៉ាងច្បាស់លាស់ចំពោះដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំក្រោមលក្ខខណ្ឌដែលមានចែងនៅខាងខ្នងនៃពាក្យស្នើសុំនេះ។**

ធ្វើនៅ ____________ ថ្ងៃទី ____________

ហត្ថលេខា (សូមសរសេរពាក្យ “បានអាន និងឯកភាព”)៖ ____________

ខ្ញុំបានរក្សាទុកលិខិតថតចំលងនៃពាក្យស្នើសុំចុះឈ្មោះទិញនេះចំនួនមួយច្បាប់ សំរាប់ជាឯកសាផ្ទាល់ខ្លួន។

# សេចក្តីអះអាង និងការសន្យា

**ពាក្យស្នើសុំចុះឈ្មោះទិញភាគរបស់ខ្ញុំ**

- តាមរយៈការវិនិយោគក្នុងការផ្តល់ជូននេះ **ខ្ញុំក្លាយទៅជាអ្នកចូលរួមនៅក្នុងផែនការនៃការសន្សំ និងកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ** (International Group Saving and Share Ownership Plan) របស់ VINCI group។
- ប្រសិនបើគ្មានករណីចាកចេញមុនកាលកំណត់ (ដូចដែលបានរៀបរាប់នៅក្នុងខិត្តប័ណ្ណព័ត៌មានសង្ខេប) នោះទេ ការវិនិយោគរបស់**ខ្ញុំនឹងត្រូវបានឃាត់ទុករយៈពេល ៣ ឆ្នាំ**។
- **សេចក្តីសម្រេចរបស់ខ្ញុំ**ក្នុងការចូលរួម ឬមិនចូលរួមនៅក្នុងការផ្តល់ជូននេះ **ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត និងផ្ទាល់ខ្លួនទាំងស្រុង**។ សេចក្តីសម្រេចរបស់ខ្ញុំនឹងមិនមានឥទ្ធិពលមិនថាវិជ្ជមាន ឬអវិជ្ជមានក្តី ទៅលើការងាររបស់ខ្ញុំនៅក្នុង VINCI group ឡើយ។
- ការចូលរួមនៅក្នុងការផ្តល់ជូននេះមានលក្ខណៈដាច់ដោយឡែក ពីកិច្ចសន្យាការងាររបស់ខ្ញុំ។ **វាមិនបានផ្តល់អោយខ្ញុំនូវសិទ្ធិ ឬអំណាចណាមួយដែលទាក់ទងនឹងការងាររបស់ខ្ញុំ (រួមមានការគណនាការបង់ប្រាក់អតីតភាពការងារ ប្រសិនបើពាក់ព័ន្ធ) ឬផលប្រយោជន៍ដែលពាក់ព័ន្ធ ឬសិទ្ធិអំណាចណាមួយឡើយ** រាប់បញ្ចូលទាំងការបញ្ចប់កិច្ចសន្យា។
- **ឯកសារនេះ និងលិខិតផ្សេងៗទៀត**ដែលត្រូវបានចែកចាយ ឬអាចផ្តល់មកអោយខ្ញុំទាក់ទងនឹងការផ្តល់ជូននេះ ឬ ផែនការនៃការសន្សំ និងកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Saving and Share Ownership Plan) របស់ VINCI group **មិនផ្តល់ អោយខ្ញុំនូវសិទ្ធិ ឬអំណាចណាមួយទាក់ទងនឹងការផ្តល់ជូនណាមួយនាពេលអនាគតឡើយ**។

**បម្រាមៈ**

ការផ្តល់ជូននេះ គឺសម្រាប់តែនិយោជិតរបស់ VINCI group ដែលមានលក្ខខណ្ឌគ្រប់គ្រាន់តាម សមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេតែប៉ុណ្ណោះ។ ការចូលរួមក្នុងការផ្តល់ជូននេះ ត្រូវបានហាមឃាត់មិនឱ្យ ផ្តល់ជូនបុគ្គលផ្សេងទៀត ដែលមិនមែនជានិយោជិតដែលមានលក្ខខណ្ឌគ្រប់គ្រាន់។ ប្រការនេះមាន ន័យថាប្រសិនបើលោកអ្នកជានិយោជិតដែលមានលក្ខខណ្ឌគ្រប់គ្រាន់ លោកអ្នកមិនអាចផ្តល់ការចូលរួមក្នុងការផ្តល់ជូននេះដោយផ្ទាល់ ឬ ដោយប្រយោលទៅឱ្យមិត្តភក្តិ គ្រួសារ ឬបុគ្គលផ្សេងទៀតឡើយ។ ទាំងនេះរាប់បញ្ចូលទាំងការចាត់ចែងណាមួយដែលតាមរយៈនោះ អ្នកទទួលបានហិរញ្ញប្បទានជាថ្នូរនឹងការផ្តល់ភាគហ៊ុនដើម្បីទទួលបានប្រាក់ចំណេញ។

VINCI រក្សាសិទ្ធិក្នុងការចាត់វិធានការដែលខ្លួនយល់ថាចាំបាច់ ឬដែលសមគួរដើម្បីធានាអនុលោមភាពជាមួយនឹងការហាមឃាត់ក្នុងការផ្តល់ការចូលរួមក្នុងការផ្តល់ជូននេះ ទៅឱ្យបុគ្គលណាមួយដែល មិនមែនជានិយោជិតដែលមានលក្ខខណ្ឌគ្រប់គ្រាន់។ វិធានការនេះអាចរាប់បញ្ចូលទាំងការតម្រូវ អោយអ្នកចូលរួមក្នុងការផ្តល់ជូននេះផ្តល់ភស្តុតាងដែលបញ្ជាក់ថាថវិការដែលពួកគេប្រើប្រាស់ដើម្បី ទិញភាគហ៊ុនបានមកពីធនធានផ្ទាល់របស់ពួកគេ។ ប្រសិនបើ VINCI ជឿជាក់ ឬសង្ស័យថា (ទោះក្នុង ពេលណាក៏ដោយ និង ដោយពុំចាំបាច់ជូនដំណឹងជាមុន) បុគ្គលណាមួយបាន ឬអាចបំពានលើវិធាននេះ ឬលក្ខខណ្ឌផ្សេងទៀតនៃការផ្តល់ជូននេះ ទៅតាមការកំណត់ក្នុងច្បាប់ដែលពាក់ព័ន្ធ VINCI អាច (i) បដិសេធ ឬលុបចោល ពាក្យស្នើសុំចុះឈ្មោះទិញភាគហ៊ុនរបស់បុគ្គលនោះ និង ឬ/(ii) ធ្វើអោយមានការលក់ភាគហ៊ុនណាមួយដែលបានបែងចែកទៅអោយបុគ្គលនោះ និងដកហូតពីប្រាក់ដែលទទួលបានពីការលក់នូវប្រាក់ចំណេញការចំណាយ និងឬ ទឹកប្រាក់ដែល/ត្រូវបានកេងបន្លំ និង ឬ/(iii) បង្កកគណនីផែនការសន្សំរបស់បុគ្គលនោះ និង/ឬ (iv) កាត់ទុកទឹកប្រាក់ដែលត្រូវបានកេងបន្លំ ពីចំនួនទឹកប្រាក់ផ្សេងៗដែលត្រូវផ្តល់អោយ ទៅបុគ្គលនោះ ដោយក្រុមហ៊ុនណាមួយរបស់ VINCI group (រាប់បញ្ចូលទាំងប្រាក់បៀវត្សរបស់ពួកគេ)។

VINCI រក្សាសិទ្ធិក្នុងការលុបចោល ឬកែប្រែការផ្តល់ជូននេះ ទាំងមូល ឬមួយផ្នែកនៅគ្រប់ពេលវេលាទាំងអស់ ដោយយោងទៅតាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួន ផ្ទាល់។ គ្មានសំណងណាមួយត្រូវ បានចាត់ទុកថា នៅជំពាក់ ឬត្រូវបានផ្តល់អោយសំរាប់ការបាត់បង់នូវទឹកចិត្ត ឬផលចំណេញនាពេល អនាគត ណាមួយឡើយ ក្នុងករណីលុបចោល ឬកែប្រែនេះ។

ខ្ញុំយល់ថា នាពេលបច្ចុប្បន្ន មិនមានច្បាប់ជាក់លាក់ណាមួយដែលគ្រប់គ្រងការផ្តល់ជូនក្នុងប្រទេសកម្ពុជា។ ក្នុងករណីនៃការអនុម័តច្បាប់ ឬ ការអនុម័ត បទប្បញ្ញត្តិ VINCI រក្សាសិទ្ធិក្នុងការប្រែលក្ខខណ្ឌនៃការផ្តល់ជូននេះតាមកម្រិតដែលតម្រូវតាមច្បាប់នៃប្រទេសកម្ពុជា។ ខ្ញុំយល់ព្រម ក្នុងការចង់ភ្ជាប់ដោយការកែប្រែទាំងអស់នោះ និង/ឬ កាតព្វកិច្ចផ្លូវច្បាប់បន្ថែមដែលទាមទារនៅក្រោមច្បាប់នៃប្រទេសកម្ពុជា ដើម្បីអនុវត្តការផ្តល់ជូននៅក្នុងប្រទេសកម្ពុជាប្រកប ដោយប្រសិទ្ធភាព។

**ការរឹតត្បិតជាក់លាក់**

**ការផ្តល់ជូននេះមិនផ្តល់ឲ្យ "ជនជាតិអាមេរិក"។ ខ្ញុំបញ្ជាក់ថា ខ្ញុំមិនមែនជាអ្នកស្នាក់នៅសហរដ្ឋអាមេរិកឡើយ។**

យោងតាមវិធាន (EU) លេខ ៨៣៣/២០១៤ និងវិធាន (EC) លេខ ៧៦៥/២០០៦ (ដែលបានធ្វើវិសោធនកម្ម) **ការផ្តល់ជូននេះមិនត្រូវបានធ្វើឡើងចំពោះជនជាតិរុស្ស៊ី និងបុគ្គលដែលស្នាក់នៅក្នុងប្រទេសរុស្ស៊ី ឬជនជាតិបេឡារុស្ស និងបុគ្គលដែលស្នាក់នៅក្នុងប្រទេសបេឡារុស្សទេ** លើកលែងតែ (i) ក្នុងករណីជនជាតិរុស្ស៊ី ប្រសិនបើបុគ្គលទាំងនោះជាជនជាតិនៃរដ្ឋសមាជិកសហភាពអឺរ៉ុប នៃប្រទេសជាសមាជិកនៃតំបន់សេដ្ឋកិច្ចសហភាពអឺរ៉ុប ឬ ប្រទេសស្វីស ឬមានសិទ្ធិស្នាក់នៅបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍នៅក្នុងរដ្ឋសមាជិកនៃសហភាពអឺរ៉ុប ប្រទេសជាសមាជិកនៃតំបន់សេដ្ឋកិច្ចសហភាពអឺរ៉ុប ឬប្រទេសស្វីស និង (ii) ក្នុងករណីជនជាតិបេឡារុស្ស ប្រសិនបើបុគ្គលទាំងនោះជាជនជាតិនៃរដ្ឋសមាជិកសហភាពអឺរ៉ុប ឬមានសិទ្ធិស្នាក់នៅបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុប។

ខ្ញុំសូមបញ្ជាក់ថា ការរឹតត្បិតនេះមិនអនុវត្តចំពោះខ្ញុំឡើយ។

**ការទូទាត់ និងភាគហ៊ុនបន្ថែមរបស់ខ្ញុំ**

- ខ្ញុំសូមបញ្ជាក់ថា ប្រាក់ដែលខ្ញុំបង់សម្រាប់ការវិនិយោគនៅក្នុងផែនការនៃការសន្សំ និងការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Share Ownership Plan) របស់ VINCI group ក្នុងឆ្នាំ២០២៦ **នឹងមិនលើសពី ២៥% នៃប្រាក់សំណងដុលប្រចាំឆ្នាំរបស់ខ្ញុំដែលត្រូវបានប៉ាន់ស្មានសម្រាប់ឆ្នាំ២០២៦ ឡើយ**។
  ១. គោលបំណងនៃការគណនានេះ ខ្ញុំនឹងគិតពិចារណាអំពីប្រាក់ខែដែលបានបង់ឲ្យខ្ញុំចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ ហើយធ្វើការប៉ាន់ស្មានអំពីប្រាក់ខែដែលខ្ញុំគួរទទួលបានរហូតដល់ដំណាច់ឆ្នាំ២០២៦ ដោយផ្អែកលើកិច្ចសន្យាការងាររបស់ខ្ញុំ។
  ២. តួលេខទាំងអស់ដែលបានរក្សាទុកសម្រាប់ការគណនានេះជាចំនួនសរុប ពោលគឺមុនពេលបង់ពន្ធកាត់ទុក និងរបបសន្តិសុខសង្គមដែលអាចមាន។
- ខ្ញុំយល់ថា ទោះបីជាខ្ញុំនឹងត្រូវបង់ថ្លៃសំរាប់ការវិនិយោគរបស់ខ្ញុំជារូបិយប័ណ្ណដុល្លារអាមេរិក ("**USD**") ក៏ដោយ ការចុះឈ្មោះទិញឯកតារបស់ VINCI ត្រូវធ្វើឡើងជារូបិយបណ្ណអឺរ៉ូ ("**Euros**") ។ ដូចនេះ ចំនួនទឹកប្រាក់នៃការវិនិយោគរបស់ខ្ញុំនឹងត្រូវគណនាដោយយោងតាមតម្លៃចុះឈ្មោះទិញជាអឺរ៉ូ និងត្រូវប្តូរទៅជាដុល្លារអាមេរិក ដោយផ្អែកទៅតាមអត្រាប្តូរប្រាក់ដែលកំណត់ដោយ VINCI នៅកាលបរិច្ឆេទនៃការកំណត់តម្លៃនេះ (មានន័យថាថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៦)។ VINCI ត្រូវបានប្រមាណទុកថានឹងប្រើប្រាស់នូវអត្រាប្តូរប្រាក់ ដែលមានប្រសិទ្ធភាពអនុវត្តនៅកាលបរិច្ឆេទនោះ។ ក្នុងអំឡុងពេលនៃដំណើរការនៃការវិនិយោគរបស់ខ្ញុំ តម្លៃនៃទ្រព្យសម្បត្តិរបស់ខ្ញុំនឹង ត្រូវទទួលរងឥទ្ធិពលដោយការប្រែប្រួលនៃអត្រាប្តូរប្រាក់រវាងប្រាក់អឺរ៉ូ និង ប្រាក់ដុល្លារអាមេរិក។ អាស្រ័យហេតុនេះ ប្រសិនបើតម្លៃនៃប្រាក់អឺរ៉ូឡើងថ្លៃបើធៀបទៅនឹងប្រាក់ដុល្លារអាមេរិក តម្លៃនៃទ្រព្យសម្បត្តិរបស់ខ្ញុំ ដែលបង្ហាញជាប្រាក់ដុល្លារអាមេរិកនឹងកើនឡើងផងដែរ។ ផ្ទុយមកវិញ ប្រសិន បើតម្លៃនៃប្រាក់អឺរ៉ូថយចុះបើធៀបទៅនឹងតម្លៃប្រាក់ដុល្លារអាមេរិក តម្លៃនៃទ្រព្យសម្បត្តិរបស់ខ្ញុំដែលបង្ហាញជាប្រាក់ដុល្លារអាមេរិកនឹងធ្លាក់ចុះផងដែរ។
- **បន្ថែម**លើការវិនិយោគរបស់ខ្ញុំ VINCI នឹងផ្តល់ឲ្យខ្ញុំនូវភាគហ៊ុន**របស់ VINCI ដោយឥតគិតថ្លៃ (ភាគហ៊ុនបន្ថែម)** ស្របតាមលក្ខខណ្ឌដែលបានរៀបរាប់នៅក្នុងខិត្តប័ណ្ណព័ត៌មានសង្ខេប។

**ការវិនិយោគរបស់ខ្ញុំ**

- រាល់លក្ខខណ្ឌទាំងឡាយដែលគ្រប់គ្រងលើការវិនិយោគ និងសិទ្ធិក្នុងការទទួលបានភាគហ៊ុនបន្ថែម មានចែងក្នុងផែនការនៃការសន្សំ និងការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Saving and Share Ownership Plan) របស់ VINCI group នៅក្នុងពាក្យស្នើសុំចុះឈ្មោះទិញនេះ នៅក្នុងវិធាននានា និងឯកសារសំខាន់ៗរបស់ FCPE Castor

International Relais 2026 និង FCPE Castor International ឯកសារបន្ថែមប្រចាំប្រទេស និងលិខិតបញ្ជាក់ដោយសាម៉ីខ្លួន អាចរកបាននៅ castor.vinci.com។

- តម្លៃនៃការវិនិយោគរបស់ខ្ញុំ**នឹងប្រែប្រួលតាមតម្លៃភាគហ៊ុនរបស់ VINCI** ដែលបានចុះបញ្ជីនៅក្នុង Euronext ដែលអាចឡើង ឬចុះផងដែរ។
- ខ្ញុំអាចចូលក្នុង www.vinci.com ទៅកាន់ឯកសារចុះបញ្ជីជាសកលរបស់ VINCI និងរបាយការណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលមានចែងនូវ**ព័ត៌មានសំខាន់ៗ**ស្តីពីសកម្មភាព កត្តាហានិភ័យ យុទ្ធសាស្ត្រ និងលទ្ធផលហិរញ្ញវត្ថុរបស់ VINCI។

## ការផ្តល់ជូន និងការកាត់បន្ថយនៅក្នុងករណីនៃការទិញលើស

- ចំនួនភាគហ៊ុនដែលមានក្នុងការផ្តល់ជូននេះ គឺ ៨ ៨០៤ ០០៦។ ប្រសិនបើចំនួនសរុបនៃសំណើរ ចុះឈ្មោះទិញលើសពីចំនួនភាគហ៊ុនដែលមានសំរាប់ការផ្តល់ជូននេះ ចំនួនទឹកប្រាក់នៃការវិនិយោគរបស់ខ្ញុំនឹងត្រូវកាត់បន្ថយ។ ចំនួនដែលត្រូវកាត់បន្ថយនេះនឹងត្រូវគណនាដូចខាងក្រោម៖
  ១. កម្រិតកំណត់ដាច់ដោយឡែកមួយនឹងត្រូវបានគណនាអោយស្មើនឹងសំណើរចុះឈ្មោះទិញជា មធ្យម ដែលគណនាដោយផ្អែកលើចំនួននៃសំណើរចុះឈ្មោះទិញសរុប។ សំណើរចុះឈ្មោះទិញនឹងត្រូវទទួលយកយ៉ាងពេញលេញរហូតដល់កម្រិតដែលកំណត់នេះ។
  ២. បន្ទាប់មក ចំនួនភាគហ៊ុនដែលនៅសល់នឹងត្រូវបានកំណត់ ហើយសមាមាត្រនៃការកាត់បន្ថយនឹងត្រូវគណនា និងបានអនុវត្តចំពោះសំណើរចុះឈ្មោះទិញនីមួយៗដែលនៅសល់។
- **ខ្ញុំយល់ព្រមកាត់បន្ថយចំនួនវិនិយោគរបស់ខ្ញុំ ចុះមកត្រឹមចំនួនភាគហ៊ុនទាំងអស់ដែលបានគណនាតាមនោះផងដែរ**។ ចំនួនទឹកប្រាក់ដែលនៅសល់ពីការបង់ប្រាក់របស់ខ្ញុំ នឹងត្រូវសងមកអោយខ្ញុំវិញ ឬចំនួនដែលត្រូវកាត់ទុកត្រូវកាត់បន្ថយតាមនោះដែរ។

## ពន្ធ

- ខ្ញុំបានកត់សំគាល់អំពីផលវិបាកផ្នែកពន្ធដារ ដែលអាចកើតចេញពីការចូលរួមរបស់ខ្ញុំក្នុងការផ្តល់ជូននេះ និង **សូមទទួលខុសត្រូវពេញលេញលើបញ្ហានេះ**។
- ជាពិសេស ខ្ញុំទទួលស្គាល់ថា ខ្ញុំត្រូវសងនិយោជកវិញនូវចំនួនទឹកប្រាក់ទាំងឡាយណាដែលនិយោជកបានបង់ជាមុនជំនួសខ្ញុំ សំរាប់ថ្លៃបន្ថែកពន្ធដារ ឬបន្ថែករបបសន្តិសុខសង្គមដែលជាក់ស្តែងត្រូវអនុវត្តមកលើរូបខ្ញុំផ្ទាល់។ និយោជករបស់ខ្ញុំ អាចកាត់នូវចំនួនទឹកប្រាក់នេះចេញពីប្រាក់បៀវត្សរបស់ខ្ញុំ ឬ ពីប្រាក់ផ្សេងទៀតដែលត្រូវបង់មកអោយខ្ញុំ។ ប្រសិនបើចាំបាច់ និយោជករបស់ខ្ញុំក៏អាច៖
  - បញ្ជាអោយលក់នូវឯកតា FCPE ឬភាគហ៊ុនរបស់ខ្ញុំ។ និង
  - កាត់ទុកពីប្រាក់ចំណូលពីការលក់ដែលបានចែងខាងលើ។

## ការខកខានក្នុងការទូទាត់ - ការទូទាត់យឺតយ៉ាវ

- ប្រសិនបើការគណនាចំនួនទឹកប្រាក់វិនិយោគសរុបមិនត្រឹមត្រូវ និងមិនស្របតាមចំនួនភាគហ៊ុនដែលខ្ញុំបានសម្រេចវិនិយោគ **សំណើរបស់ខ្ញុំនឹងត្រូវដំណើរការតាមចំនួនភាគហ៊ុនដែលបានបញ្ជាក់** ហើយ**ខ្ញុំនឹងនៅតែទទួលខុសត្រូវចំពោះនិយោជកសម្រាប់ភាពខុសគ្នា**។ ខ្ញុំទទួលស្គាល់ និងយល់ព្រមយ៉ាងច្បាស់ថា និយោជកអាចដកស្រង់ភាពខុសគ្នានោះតាមរយៈការកាត់ប្រាក់ខែ ឬយល់ព្រមលើវិធីសាស្ត្រសងប្រាក់ផ្សេងទៀត។ ក្នុងករណីមានការទូទាត់លើស ខ្ញុំនឹងត្រូវបានសងប្រាក់វិញ។
- ប្រសិនបើខ្ញុំខកខានមិនបានបង់ ឬមិនធ្វើការបង់ប្រាក់សំរាប់ការវិនិយោគរបស់ខ្ញុំតាមពេលវេលាកំណត់ទេនោះ ការស្នើសុំទិញភាគហ៊ុននេះ អាចត្រូវបានលុបចោលដោយមិនចាំបាច់មានការផ្តល់ដំណឹងឡើយ។
- ប្រសិនបើការស្នើសុំទិញរបស់ខ្ញុំត្រូវបានដំណើរការ ខ្ញុំនឹងនៅតែមានទំនួលខុសត្រូវចំពោះនិយោជករបស់ខ្ញុំសម្រាប់ទឹកប្រាក់នៃការចុះឈ្មោះទិញរបស់ខ្ញុំ។
- ខ្ញុំទទួលស្គាល់ និងយល់ព្រមយ៉ាងច្បាស់លាស់ថា VINCI អាចលោះត្រឡប់វិញ ឬបានលោះមកវិញនូវរាល់ឯកតា FCPE និង/ឬ ភាគហ៊ុនរបស់ខ្ញុំទាំងអស់ និងកាត់កងប្រាក់ដែល ទទួលបានមកពីការលក់មកធ្វើការទូទាត់ថ្លៃទិញរបស់ខ្ញុំដោយមិនចាំបាច់មានការជូនដំណឹងជាមុនឡើយ។

- ប្រសិនបើប្រាក់ដែលទទួលបានមកពីការលក់ មិនគ្រប់គ្រាន់នឹងទូទាត់សងចំនួនទឹកប្រាក់ដែលបានបង្ហាញខាងលើ ខ្ញុំនឹងនៅតែជំពាក់ VINCI SA នូវចំនួនទឹកប្រាក់ដែលសមមូលនឹងប្រាក់ជំពាក់។
- VINCI SA នៅរក្សាសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងចំពោះរូបខ្ញុំ ដើម្បីទាមទារប្រាក់ដែលនៅជំពាក់។

**ដំណើរការទិន្នន័យផ្ទាល់ខ្លួន**

- ទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំដែលមាននៅ ក្នុងពាក្យស្នើសុំនេះត្រូវប្រើក្នុងបរិបទនៃការដំណើរការទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ ស្ថិតនៅក្រោមៈ
  - បទប្បញ្ញត្តិច្បាប់បារាំងលេខ ៧៨-១៧ នៃថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ ស្តីពីការដំណើរការទិន្នន័យ។ និង
  - បទប្បញ្ញត្តិរបស់សហគមន៍អឺរ៉ុបស្តីពីការការពារទិន្នន័យ (២០១៦/៦៧៩)។
- ទិន្នន័យដែលមាននៅក្នុងពាក្យស្នើសុំនេះចាំបាច់ក្នុងការចុះហត្ថលេខាលើកិច្ចសន្យាចុះឈ្មោះទិញ និងក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្ញុំក្នុងក្របខណ្ឌនៃផែនការនៃការសន្សំ និងការកាន់កាប់ភាគហ៊ុនរបស់និយោជិតជាអន្តរជាតិ (International Group Saving and Share Ownership Plan) របស់ VINCI group។
- ទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំនឹងត្រូវបានរក្សាទុកៈ
  - ក្នុងរយៈពេលដែលចាំបាច់ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្ញុំ ដែលត្រូវស្របទៅនឹងរយៈពេលហាមឃាត់ការលក់ (lock-up period) ដែលបានកំណត់ក្រោមផែនការនេះ។
  - បន្ទាប់ពីការរំលោះទ្រព្យសម្បត្តិ (សម្រាប់គោលបំណងរក្សាទុក) រហូតដល់ផុតកំណត់នៃរយៈពេលនៃជម្លោះដែលអាចកើតមាន។
- អ្នកបញ្ជាលើដំណើរការទិន្នន័យគឺ **ក្រុមហ៊ុន VINCI S.A** .។
- ទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំ**នឹងត្រូវបានផ្ទេរឲ្យ AMUNDI ESR** នៅប្រទេសបារាំង ដែលត្រូវបានតែងតាំងដោយក្រុមហ៊ុន VINCI S.A.ឱ្យប្រតិបត្តិរាល់ប្រតិបត្តិការដែលពាក់ព័ន្ធនឹងសំណើរចុះឈ្មោះទិញរបស់ខ្ញុំ ការរក្សាគណនី និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្ញុំ។
- ខ្ញុំមាន**សិទ្ធិក្នុងការស្នើសុំៈ**
  - ចូលមើល កែប្រែ កែតម្រូវ ឬលុបចោល (បន្ទាប់ពីការលោះទ្រព្យសម្បត្តិរបស់ខ្ញុំទាំងអស់ដែលមានក្នុងគម្រោង) នូវទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំ។
  - សិទ្ធិក្នុងការស្នើសុំការរឹតត្បិតលើការដំណើរការទិន្នន័យរបស់ខ្ញុំ ឬតវ៉ាចំពោះការដំណើរការ។
  - សិទ្ធិក្នុងការផ្ទេរទិន្នន័យ។ និង
  - សិទ្ធិក្នុងការដាក់ពាក្យបណ្តឹងទៅអាជ្ញាធរត្រួតពិនិត្យ។
- **ដើម្បីអនុវត្តសិទ្ធិរបស់ខ្ញុំ ខ្ញុំត្រូវទំនាក់ទំនងទៅៈ** contact.dpo@vinci.com។
- **ព័ត៌មាន**ស្តីពីដំណើការទិន្នន័យផ្ទាល់ខ្លួននៅក្នុងបរិបទនៃការផ្តល់ជូន មាននៅ **castor.vinci.com**។